# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**ទីស្តីការគណៈរដ្ឋមន្ត្រី**

**ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ**

# សុន្ទរកថា

## ដោយ

## ឯកឧត្តម សុខ ស៊ីឡូ អគ្គលេខាធិការរងនៃក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ

## ក្នុងឱកាសបើកកិច្ចស្តីពី ការបង្កើតបណ្តាញមន្ត្រីបច្ចេកទេសអន្តរក្រសួង-ស្ថាប័ន សម្រាប់ការគ្រប់គ្រងព័ត៌មាន និងចំណេះដឹងលើវិស័យកសិកម្មនិងជនបទ

អាគារទីស្តីការគណៈរដ្ឋមន្ត្រី, ថ្ងៃទី១៨ ខែសីហា ឆ្នាំ ២០១០

- *ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវកិត្តិយសជាតិ និង អន្តរជាតិ ជាទីគោរព!*

១- ថ្ងៃនេះ ខ្ញុំមានសេចក្តីរីករាយជាអនេកដោយបានចូលរួមជាមួយឯកឧត្តម លោកជំទាវ លោក លោកស្រីទាំងអស់ក្នុងកិច្ចប្រជុំស្តីពី **ការបង្កើតបណ្តាញមន្ត្រីបច្ចេកទេសអន្តរក្រសួង-ស្ថាប័នសម្រាប់ការគ្រប់គ្រងព័ត៌មាននិងចំណេះដឹងលើវិស័យកសិកម្មនិងជនបទ** ដែលរៀបចំដោយក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ(ក.ក.ជ.) ក្នុងក្របខ័ណ្ឌគម្រោងកសាងសមត្ថភាពសហគមន៍ ដើម្បីកាត់បន្ថយភាពក្រីក្រនៅតំបន់ជុំវិញបឹងទន្លេសាប ដែលមានឯកឧត្តម **គួច ប៊ុនហួរ** អគ្គលេខាធិការរងនៃក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ជានាយកគម្រោង ។

២- ក្នុងនាមឯកឧត្តមឧបនាយករដ្ឋមន្ត្រី **យឹម ឆៃលី** ប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំមានកិត្តិយស និង សូមសំដែងនូវការកោតសរសើរដោយស្មោះចំពោះសហការីរបស់ខ្ញុំ នៅក្នុងក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ដែលបានសហការជាមួយធនាគារអភិវឌ្ឍន៍អាស៊ី ADB អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការអភិវឌ្ឍន៍ បច្ចេកវិទ្យា គមនាគមន៍ ព័ត៌មាន NIDA

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងអភិវឌ្ឍន៍ជនបទ វិទ្យាស្ថានបណ្តុះបណ្តាលនិងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា CDRI វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជាCARDI និងស្ថាប័នពាក់ព័ន្ធ អង្គការជាតិ-អន្តរជាតិ និងដៃគូអភិវឌ្ឍនានា ក្នុងការរៀបចំកិច្ចប្រជុំនាថ្ងៃនេះឲ្យចេញជារូបរាងឡើង។ ជាមួយគ្នានេះដែរ ខ្ញុំសូមវាយតម្លៃខ្ពស់ចំពោះ វត្តមានរបស់ ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលបានឆ្លៀតពេលវេលាដ៏មមាញឹក ដើម្បីចូលរួម កិច្ចប្រជុំដ៏មានសារៈសំខាន់នេះ។

៣- ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមអនុញ្ញាតធ្វើការចាប់អារម្មណ៍ និងបញ្ជាក់ជូនឯកឧត្តម លោកជំទាវ លោក លោកស្រី មេត្តាជ្រាបថា៖ ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ កំពុងតែពង្រឹងតួនាទីរបស់ខ្លួននៅក្នុងការគ្រប់គ្រងព័ត៌មាននិងចំណេះដឹង លើវិស័យកសិកម្មនិងអភិវឌ្ឍន៍ជនបទ វិស័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ប្រពន្ធ័សុវត្ថិភាពសង្គមនៅកម្ពុជា ។ ការគ្រប់គ្រងព័ត៌មាននិងចំណេះដឹងនេះ គឺជាផ្នែកមួយនៃអណ្ណត្តិការងាររបស់ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ក្នុងការធ្វើឱ្យល្អប្រសើរឡើង នូវគេហទំព័ររបស់ខ្លួន www.card.gov.kh និង ធ្វើឱ្យល្អប្រសើរឡើងនូវយន្តការនានា ដើម្បីប្រមូលនិងចែកចាយព័ត៌មាននិងចំណេះដឹងលើវិស័យកសិកម្ម និងជនបទ វិស័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ប្រពន្ធ័សុវត្ថិភាពសង្គម ដល់ភាគីពាក់ពន្ធ័ដ៏ទៃទៀត។

៤- បច្ចុប្បន្ន មាតិការព័ត៌មាន និង ទិដ្ឋភាព គេហទំព័រ របស់ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យ កសិកម្ម និងជនបទ កំពុងតែត្រូវបានបង្កើត ជាភាសាខ្មែរ សម្រាប់គេហទំព័រ www.card.gov.kh និង គេហទំព័រ www.socialprotection.card.gov.kh ។ រាល់ទំព័របាន និងកំពុងតែត្រូវបានបកប្រែទៅជាភាសាខ្មែរ ដោយប្រើពុម្ពអក្សរខ្មែរយូនីកូដ ដើម្បីផ្តល់នូវការទទួលបានព័ត៌មានដ៏ល្អបំផុតដែលអាចធ្វើទៅបាន។ ភាសាខ្មែរត្រូវបានប្រើនៅក្នុងទំព័រដើមរួមជាមួយនិងទំព័រឆ្លាស់គ្នាមួយទៀតគឺភាសាអង់គ្លេស។ ផ្នែកសំខាន់មួយទៀតនៃគេហទំព័រដែលត្រូវបានកែលំអគឺច្រកចេញ-ចូលព័ត៌មាន កសិកម្ម និងអភិវឌ្ឍន៍ជនបទនៅកម្ពុជា (CARDiG)។ ការធ្វើបែបនេះ គឺដើម្បីទទួលបានព័ត៌មានថ្មីៗ ឆាប់រហ័សនិងងាយស្រួលស្តីពីវិស័យកសិកម្មនិងអភិវឌ្ឍន៍ជនបទនៅកម្ពុជា។ ច្រកចេញ-ចូលព័ត៌មានកសិកម្មនិងអភិវឌ្ឍន៍ជនបទនៅកម្ពុជា បានភ្ជាប់ទំនាក់ទំនងទៅកាន់គេហទំពរ័របស់ក្រសួង-ស្ថាប័ន អង្គការជាតិនិងអន្តរជាតិនានា ដែលក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ បានធ្វើការសម្របសម្រួលយ៉ាងជិតស្និទ្ធជាមួយ។

៥- ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទបានពិនិត្យឃើញថា ការបង្កើតគេហទំព័ររបស់ក្រសួង-ស្ថាប័ននានា នៅកម្ពុជា ស្ថិតនៅក្នុងល្បឿន និងវិធីសាស្រ្តខុសៗគ្នា ជាច្រើន។ កិច្ចការរបស់ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ក្នុងការសម្របសម្រួលវិស័យកសិកម្មនិងអភិវឌ្ឍន៍ជនបទ មានភាពលំបាកនិងស្មុគស្មាញជាខ្លាំង ដោយសារតែមានកម្រិតថ្នាក់ខុសៗគ្នានៃជំនាញ ក្នុងការរៀបចំគេហទំព័រ និងការមិនបើកទូលាយក្នុងការចែកចាយ ព័ត៌មាន និងចំណេះដឹងឲគ្នាទៅវិញ ទៅមក។ ឧទាហរណ៍ ការប្រើប្រាស់ពុម្ពអក្សរខ្មែរយូនីកូដ ការរចនាគេហទំព័រ ការរៀបចំកម្មវិធី និងការប្រើប្រាស់

ប្រព័ន្ធគ្រប់គ្រងមាតិការគេហទំព័ររបស់ក្រសួង-ស្ថាប័ន និមួយៗតែងតែមានភាពមិនដូចគ្នាទេ ហើយបច្ចុប្បន្ន គេហទំព័រមួយចំនួនមិនត្រូវបានបង្ហោះព័ត៌មានថ្មីៗ និងមិនបានធ្វើបច្ចុប្បន្នកម្មទៀងទាត់ឡើយ។

*ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវកិត្តិយសជាតិ និង អន្តរជាតិ ជាទីគោរព!*

៦- ដើម្បីរួមចំណែកក្នុងការបំពេញនូវចន្លោះប្រហោង និងដោះស្រាយនូវបញ្ហាប្រឈមនានា ដែលបានកើតមានឡើងក្នុងការចែករំលែកព័ត៌មាននិងចំណេះដឹងលើវិស័យកសិកម្ម និងជនបទ ថ្ងៃនេះ ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ បានរៀបចំប្រជុំ ស្តីពី **ការបង្កើតបណ្តាញមន្ត្រីបច្ចេកទេសអន្តរក្រសួង-ស្ថាប័នសម្រាប់ការគ្រប់គ្រងព័ត៌មាន និងចំណេះដឹងលើវិស័យកសិកម្មនិងជនបទ** ក្នុងគោលបំណង ដូចខាងក្រោម៖

- ផ្លាស់ប្តូរបទពិសោធន៍នៅក្នុងប្រព័ន្ធគ្រប់គ្រងព័ត៌មាននិងចំណេះដឹង
- ផ្លាស់ប្តូរបទពិសោធន៍ទៅលើបញ្ហាបច្ចេកទេសស្តីពីការបង្កើតគេហទំព័រ ប្រព័ន្ធគ្រប់គ្រង ទិន្នន័យដោយផ្អែកទៅលើគេហទំព័រ ការបង្ហោះគេហទំព័រ ប្រព័ន្ធគ្រប់គ្រងព័ត៌មាន នៅក្នុងគេហទំព័រ ពុម្ពអក្សរខ្មែរយូនីកូដ និងជំនាញកំព្យូទ័រផ្សេងៗទៀត
- បង្កើតបណ្តាញមន្ត្រីបច្ចេកទេសមួយសម្រាប់ជួយគ្នាទៅវិញទៅមក
- ធ្វើឱ្យប្រសើរឡើងនូវការផ្លាស់ប្តូរ ព័ត៌មាននិងចំណេះដឹងនៅកម្ពុជា។

៧- ដូច្នេះ យើងជួបជុំគ្នានៅថ្ងៃនេះ គឺដើម្បីពិភាក្សាស្វែងយល់ ផ្លាស់ប្តូរបទពិសោធន៍ ចែករំលែកព័ត៌មាន ឲ្យបានកាន់តែស៊ីជម្រៅអំពីបញ្ហាចន្លោះប្រហោង និងកង្វះខាតនានា ដែលកើតមានឡើង នៅក្នុងការប្រតិបត្តិ ការងារប្រចាំថ្ងៃ និងដើម្បីស្វែងរកវិធីសាស្ត្រ ដំណោះស្រាយសមស្រប សំដៅធានាឲ្យមានយន្តការទំនាក់ទំនង និងចែករំលែកព័ត៌មាននិងចំណេះដឹងឲកាន់តែប្រសើរឡើងនិងសម្រេចឲបាននូវគោលបំណងខាងលើ ។

*ឯកឧត្តម លោកជំទាវ លោក លោកស្រី!*

៨- ក្នុងនាម ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **យឹម ឆៃលី** និងជាប្រធាន ក.ក.ជ. ខ្ញុំសូមធ្វើការអំពាវនាវឲ្យមានកិច្ចសហប្រតិបត្តិការ និង សម្របសម្រួលល្អប្រសើរ ក្នុងចំណោមភាគីពាក់ព័ន្ធនានា ដើម្បីសម្រេចគោលដៅ **បង្កើតបណ្តាញមន្ត្រីបច្ចេកទេស អន្តរក្រសួង-ស្ថាប័នសម្រាប់ការគ្រប់គ្រងព័ត៌មាន និងចំណេះដឹងលើវិស័យកសិកម្មនិងជនបទ** និងយន្តការសម្របសម្រួលឲមានប្រសិទ្ធភាព។ ខ្ញុំមានជំនឿជឿជាក់យ៉ាងមុតមាំថា កិច្ចប្រជុំនាថ្ងៃនេះ នឹងផ្តល់ជូនឯកឧត្តម លោកជំទាវ លោក លោកស្រី យល់កាន់តែច្បាស់ពីបញ្ហា និងឱកាសថ្មីៗនៃការបង្ហោះគេហទំព័រនៅកម្ពុជា ការណែនាំឲស្គាល់ពីគេហទំព័រថ្មី និងព័ត៌មានសំខាន់ៗ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងអភិវឌ្ឍន៍ជនបទ

វិទ្យាស្ថានបណ្តុះបណ្តាលនិងស្រាវជ្រាវ ដើម្បីអភិវឌ្ឍន៍កម្ពុជា CDRI វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជាCARDI និងក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ។

ជាមួយគ្នានេះដែរ មតិយោបល់ និងទស្សនៈរបស់ឯកឧត្តម លោកជំទាវ លោក លោកស្រី នឹងត្រូវបានយកមកពិនិត្យពិចារណាយ៉ាងយកចិត្តទុកដាក់ជាទីបំផុត ដើម្បីជាធាតុចូលក្នុងការរៀបចំកែលំអគេហទំព័រ និងប្រព័ន្ធគ្រប់គ្រងព័ត៌មាននិងចំណេះដឹងរបស់ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ឲ្យកាន់តែមានភាពល្អប្រសើរ។ ក្នុងន័យនេះខ្ញុំប្រាកដក្នុងចិត្តថា បន្ទាប់ពីការធ្វើបទបង្ហាញដោយបណ្តាវាគ្មិន ក្នុងពេលបន្តិចទៀតនេះ ឯកឧត្តម លោកជំទាវ លោក លោកស្រី នឹងចូលរួមយ៉ាងសកម្មក្នុងការពិភាក្សា និងចែករំលែកមតិយោបល់ និង បទពិសោធន៍ល្អៗ ដល់អង្គប្រជុំរបស់យើង។

ជាចុងបញ្ចប់ អនុញ្ញាតឲ្យខ្ញុំឆ្លៀតឱកាសនេះ សូមថ្លែងអំណរគុណដល់ ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ភ្ញៀវជាតិ និងអន្តរជាតិ ដែលបានបរិច្ចាកពេលវេលាដ៏មានតម្លៃ ដើម្បីចូលរួមផ្តល់មតិយោបល់ និងទស្សនៈផ្សេងៗ ក្នុងអង្គប្រជុំ នាថ្ងៃនេះ។ ខ្ញុំសូមប្រសិទ្ធពរជ័យជូន ឯកឧត្តម លោកជំទាវ អស់លោក លោក្រសី សូមប្រកបតែសុភមង្គលដ៏ត្រចះត្រចង់ សំណាងល្អ និងទទួលនូវជោគជ័យដ៏ធំធេងនៅរាល់គ្រប់ភារកិច្ច។ ខ្ញុំក៏សូមជូនពរឲ្យអង្គប្រជុំរបស់យើងនាថ្ងៃនេះ ប្រព្រឹត្តទៅបានដោយជោគជ័យ និងទទួលលទ្ធផលជាផ្លែផ្កា។

ខ្ញុំសូមប្រកាស បើក អង្គប្រជុំស្តីពី**បង្កើតបណ្តាញមន្ត្រីបច្ចេកទេសអន្តរក្រសួង-ស្ថាប័នសម្រាប់ការគ្រប់គ្រងព័ត៌មាន និងចំណេះដឹងលើវិស័យកសិកម្មនិងជនបទ** ចាប់ពីពេលនេះទៅ។

**សូមអរគុណ**

!